# វិភាគទានដើម្បីក្លាយជាឧកញ៉ា

*ដោយ ដួង សុខា*

14-04-2008



*ភ្នំពេញ ថ្ងៃទី ២ មករា ២០០៨ការបង្ហាញមេដៃឧកញ៉ានៅ នាយកដ្ឋានគ្រឿងឥស្សរិយយស នៃទីស្តីការគណរដ្ឋមន្ត្រី*

©John Vink / Magnum

*ឧកញ៉ា គឺជាគោរមងាររមួយដ៏ខ្ពង់ខ្ពស់ ដែលប្រជាពលរដ្ឋកម្ពុជាមានទ្រព្យសម្បត្តិស្តុកស្តម្ភប្រាថ្នាចង់បាន។ គោរមងារដ៏មានកិត្តិយសនេះ ត្រូវបានបង្កើតឡើង អស់រយៈពេលជាង១០ឆ្នាំមកហើយ សម្រាបសប្បុរសជនណាដែលបានចូលរួមស្ថាបនា និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ។ ជាគោលការណ៍ ឧកញ៉ាភាគច្រើនគឺជាអ្នកជំនួញធំៗ ដែលបានប្រឡូកនៅក្នុងនយោបាយ ហើយ ឧកញ៉ាខ្លះ បានប្រើប្រាស់គោរមងារនេះប្រព្រឹត្តិទង្វើខុសច្បាប់។*

*នៅថ្ងៃទី ៥ មេសា ១៩៩៤ សហនាយករដ្ឋមន្ត្រីទាំងពីរនៅសម័យកាលនោះ គឺព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានចុះហត្ថលេខាលើអនុក្រឹត្យ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសសម្រាប់ផ្តល់អោយសប្បុរសជនណា ដែលមានស្នាដៃល្អក្នុងការស្ថាបនាប្រទេសជាតិ មិនថាជាជនជាតិខ្មែរ រឺមួយក៏បរទេស។*

*មេដាយស្ថាបនាជាតិសម្រាប់អ្នកដែលបានចូលរួមជាវិភាគទានដល់ រាជរដ្ឋាភិបាលកម្ពុជា ត្រូវបាន ចែកចេញតាមផ្លូវច្បាប់ជាបីប្រភេទ នោះគឺមេដាយមាស មេដាយប្រាក់ និងមេដាយសំរិទ្ធិ។ អ្នកទទួលបានគ្រឿងឥស្សរិយយសថ្នាក់មេដាយមាស ដែលបានផ្តល់ជាវិភាគទាន រឺគ្រឿងសម្ភារៈផ្សេងៗ ដែលមានតម្លៃលើសពីមួយសែនដុល្លារឡើងទៅ នឹងទទួលគោរមងារជាឧកញ៉ា។*

*លោក ធៀន ម៉ៅ ប្រធាននាយកដ្ឋានគ្រឿងឥស្សរិយយសនៃទីស្តីការគណៈរដ្ឋមន្ត្រី បានបញ្ជាក់ថា ឧកញ៉ាទាំងអស់មានចំនួនប្រហែលជា ២២០រូប ក្នុងចំណោមនោះ ស្ត្រីមានចំនួនតិចជាង ១០រូប ដែលបានទទួលគោរមងារដ៏មានកិត្តិយសនេះ នៅក្នុងសង្គមកម្ពុជា។ ប៉ុន្តែ ចំនួនឧកញ៉ាជាផ្លូវការនេះអាចមានចំនួនតិចជាងចំនួនពិតប្រាកដ។*

## *គោរម្យងារដែលវិវឌ្ឍតាមសម័យកាល*

*លោក ម្យេច ប៉ុណ្ណ ទីប្រឹក្សាគណៈកម្មការទំនៀមទំលាប់ខ្មែរនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានអោយដឹងថា នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា គេឃើញថាឈ្មោះឧកញ៉ាមានតាំងពីសតវត្សទី១៥ ក្រោមការគ្រប់គ្រងរាជ្យសម្បត្តិរបស់ព្រះបាទព្រះចៅពញ៉ាយាត (១៤២១-១៤៦២) មកម្ល៉េះ។*

*ដោយសំអាងលើការ ស្រាវជ្រាវផ្ទាល់ លោក ម្យេច ប៉ុណ្ណ មានប្រសាសន៍រៀបរាប់ថា «ពីស.វទី១៥ ដល់ស.វទី១៦ ឧកញ៉ាសុទ្ធសឹងតែជាអភិបាលស្រុកនិងខេត្ត ព្រមទាំងជាដៃឆ្វេងដៃស្តាំរបស់ព្រះមហាក្សត្រ ទទួលបន្ទុកផ្នែកព្រះរាជកិច្ច កងទ័ព តុលាការ និងកសិកម្ម»។ លោកបានពន្យល់ថា គោរមងារនេះមានលក្ខណៈដូចនឹង ងារជា «ឯកឧត្តម» នាពេលបច្ចុប្បន្ននេះ ដែលជាងាររបស់រដ្ឋមន្ត្រី និងអភិបាលខេត្តក្រុងដែរ។*

*ពេលវេលាចេះតែដើរទៅមុខ រីឯអត្ថន័យនៃពាក្យ ឧកញ៉ា ក៏ប្រែប្រួលទៅតាមពេលវេលាដែរ។ ដោយសំអាងលើអនុក្រឹត្យឆ្នាំ១៩៩៤ លោក ធៀន ម៉ៅ បានអះអាងថា ឧកញ៉ាលែងជាមន្ត្រីនយោបាយជាន់ខ្ពស់នៅក្នុងប្រទេសទៀតហើយ ប៉ុន្តែ គឺជាអ្នកមានគុណសម្បត្តិខ្ពស់ ក្នុងកិច្ចខិតខំប្រឹងប្រែងស្តាបនាប្រទេសជាតិឡើងវិញ។*

## *ការប្រើប្រាស់នីតិវិធីដើម្បីក្លាយជាឧកញ៉ា*

*លោក ធៀន ម៉ៅ បានពន្យល់ពីនីតិវិធីយ៉ាងលំអិតថា «ប្រសិនជាមនុស្សម្នាក់ផ្តល់ថវិកាសម្រាប់សមិទ្ធិផលសាលារៀន រឺក៏ផ្លូវថ្នល់ នៅតាមខេត្ត នោះអាជ្ញាធរឃុំ ស្រុក និងខេត្ត អាចនឹងរៀបចំសំណុំបែបបទមួយ ផ្ញើជូនក្រសួងមហាផ្ទៃ ដើម្បីទទួលស្គាល់នូវគុណសម្បត្តិរបស់សប្បុរសជននោះ។ បន្ទាប់ពីក្រសួងបានបញ្ចប់ការពិនិត្យលើឯកសារនេះរួច ក្រសួងនឹងបញ្ជូនទៅកាន់នាយកដ្ឋានគ្រឿងឥស្សរិយយស តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។*

*«ខ្ញុំពិនិត្យឯកសារទាំងនោះ ឡើងវិញរួចខ្ញុំធ្វើកំណត់ហេតុមួយបញ្ជាក់ថាសប្បុរសជន នោះពិតជាបានផ្តល់អំណោយប្រាកដមែន ហើយនាយកដ្ឋាននឹងធ្វើការពិភាក្សាគ្នា មុននឹងបញ្ជូនឯកសារ*

ទៅកាន់ទីស្ដីការគណៈរដ្ឋមន្ត្រី»។ ទីស្ដីការគណៈរដ្ឋមន្ត្រីនឹងធ្វើការសិក្សាលើឯកសារនេះ បន្ទាប់មកបញ្ជូនមកអគ្គលេខាធិការរដ្ឋាភិបាល រួចបញ្ជូនមកប្រមុខរដ្ឋាភិបាល និងជាចុងក្រោយព្រះមហាក្សត្រនឹងថ្វាយព្រះហស្ថលេខា។

គ្មានសំណុំបែបបទស្នើសុំគោរមងារណាមួយត្រូវបានច្រានចោលទេនាយកដ្ឋាន គ្រឿងឥស្សរិយយសនឹងផ្ទាកពិនិត្យសំណុំបែបបទស្នើសុំណាមួយ បើសិនជាខាង នាយកដ្ឋានវាយតម្លៃឃើញថា សំណុំបែបបទនៅមិនទាន់ត្រឹមត្រូវដែលតម្រូវអោយ ធ្វើឡើងវិញអោយបានច្បាស់លាស់។ ឯកសារនេះនឹងត្រូវបញ្ជូនត្រលប់ទៅក្រសួងមហាផ្ទៃ និងអាជ្ញាធរមូលដ្ឋានវិញដែលជាអ្នកផ្ដួចផ្ដើមធ្វើការស្នើសុំគោរមងារនេះ។

ជួនកាល ការវាយតម្លៃជាតួលេខនៃអំណោយ អាចនឹងខុស។ ច្បាប់នព្វន្តអាចបែកចែកលំដាប់ថ្នាក់ពីមួយទៅមួយបាន។ ភាពសមហេតុផលនៃអំណោយត្រូវបានចោទជាសំណួរឡើង។ លោក ធៀន ម៉ៅ បានវាយតម្លៃថា «ប្រសិនបើមនុស្សម្នាក់ជូនទូរសព្ទដៃចំនួន៣២គ្រឿង ដល់អាជ្ញាធរ។ យើងត្រូវពិភាក្សាមើលថាតើអំណោយនេះបម្រើផលប្រយោជន៍សាធារណៈ រឺមួយក៏ប្រយោជន៍បុគ្គល។ យើងអាចដឹងភ្លាមបានថា អំណោយបែបនេះមិនបានផ្ដល់ផលប្រយោជន៍សម្រាប់សាធារណៈជន ដូចជាការកសាងសាលារៀន រឺមន្ទីរពេទ្យ នោះទេ។ លោកមានប្រសាសន៍ដោយប្រុងប្រយ័ត្នថា នាយកដ្ឋានរបស់លោកមិនធ្លាប់បានបដិសេធ សំណើរសុំគោរមងាររបស់អ្នកណាម្នាក់ឡើយយើងគ្រាន់តែបង្គាប់អោយអ្នកដែល រៀបចំឯកសារ ធ្វើការកែប្រែឡើងវិញប៉ុណ្ណោះ។

លោកប្រធានបានរៀបរាប់យ៉ាង ខ្លីថា «អ្នកខ្លះ» បានទទួលមេដាយមាស និងគោរមងារជាឧកញ៉ាតាមរយៈការស្នើសុំរបស់នាយករដ្ឋមន្ត្រីដោយផ្ទាល់ ដោយមិនបានឆ្លងកាត់ក្រុមការងារនៃនាយកដ្ឋានគ្រឿងឥស្សរិយយសឡើយ។ ប៉ុន្តែ លោកសុំមិនអត្ថាធិប្បាយរឿងនេះទេ។

**តើនរណាជាឧកញ៉ា?**

ឧកញ៉ាសុទ្ធសឹងជាអ្នកជំនួញជនជាតិកម្ពុជា រឺមួយបរទេស ដែលបានផ្ដល់វិភាគទានទ្រព្យសម្បត្តិរបស់ខ្លួនមួយចំនួនដល់រដ្ឋ ជានិច្ចកាល ការផ្ដល់ហិរញ្ញវត្ថុដោយផ្ទាល់សម្រាប់ការស្ថាបនានានាដូចជាការកសាងហេដ្ឋារចនា សម្ព័ន្ធសំខាន់ៗជាដើម។ សមាជិកសភាពាណិជ្ជកម្មភ្នំពេញស្ទើរតែទាំងអស់ សុទ្ធសឹងតែចេញពីក្រុម ឧកញ៉ា។ លោកធៀន ម៉ៅ បានកត់សម្គាល់ថា បន្ទាប់ពីត្រូវបានតែងតាំងដោយអនុក្រឹត្យរួចមក ឧកញ៉ាមួយចំនួនបានចូលរួមនៅក្នុងជួររាជរដ្ឋាភិបាល ដោយបានក្លាយខ្លួនជាមន្ត្រីជាន់ខ្ពស់ និងសមាជិកសភា។ វាជាការពិតណាស់ ឧកញ៉ាសឹងតែទាំងអស់មានទំនាក់ទំនងនឹងគណបក្សកាន់អំណាច នោះគឺគណបក្សប្រជាជនកម្ពុជា ។ យោងតាមសំដីរបស់

*លោក ជាម យៀប  ប្រធានគណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភា  បានអោយដឹងថា រដ្ឋសភាមានឧកញ៉ាចំនួនបីរូប រីឯព្រឹទ្ធសភាវិញ មានចំនួន៦រូប។ លោក ឆៀន ម៉ៅ បានគូសបញ្ជាក់ថា តាមរយៈសមិទ្ធិផលស្នាដៃនិងសមត្ថភាពរបស់ពួកគេ រាជរដ្ឋាភិបាលបានអោយពួកគេទាំងនោះចូលរួមបម្រើការងារអភិវឌ្ឍន៍ប្រទេសជាតិ ដោយដាក់បញ្ចូលឧកញ៉ាទៅក្នុងស្ថាប័ននីតិបញ្ញត្តិនិងប្រតិបត្តិ។ លោកមានភាពជឿជាក់ ដោយបញ្ជាក់ថា «ទោះបីជាអ្នកទាំងនោះមានងារជាឧកញ៉ាក៏ដោយ ក៏ពួកគេអាចមានតួនាទីនៅក្នុង អាណត្តិសភាបានដែរ»។*

*ការរំលោភបំពាន...*

*នៅពេលដែលយើងចោទជាសំណួរទាក់ទងនឹងឧកញ៉ាខ្លះដែលរំលោភបំពាន គោរមងាររបស់ខ្លួនដើម្បីបំពានលើច្បាប់របស់ជនរួមជាតិរបស់ខ្លួន លោក ឆៀន ម៉ៅ អះអាងយ៉ាងម៉ឺងម៉ាត់ថា «អ្នកមានគោរមងារនេះមិនអាចធ្វើអ្វីតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។» ប៉ុន្តែ សារព័ត៌មានតែងតែផ្សព្វផ្សាយព័ត៌មាន ពីជម្លោះដីធ្លី រវាងឧកញ៉ា ជាមួយនឹងអ្នកភូមិសាមញ្ញ ដែលធ្វើអោយកិត្តិយសជាឧកញ៉ាមានកេរ្តិ៍ឈ្មោះមិនល្អ។ នៅឆ្នាំ២០០៧ របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលរបស់អង់គ្លេស Oxfam បានលើកឡើងថា ដីចំនួន ២៣,០៨% នៅកម្ពុជាគឺកាន់កាប់ដោយឧកញ៉ា ដែលជាអ្នករកស៊ីជំនួញដីធ្លីលំដាប់លេខមួយ។*

*ប្រធាននាយកដ្ឋានគ្រឿង ឥស្សរិយយសមិនបានបដិសេធថា «ឧកញ៉ាមួយចំនួនត្រូវបានកោះហៅដោយតុលាការពីបទយកឈ្មោះជាឧកញ៉ារបស់ខ្លួន ដើម្បីរំលោភបំពានច្បាប់។ ទោះបីជាករណីនេះកម្រនឹងកើតមានក៏ដោយ ក៏វាមិនមែនជាសមត្ថកិច្ចរបស់នាយកដ្ឋានរបស់លោកដែរ ប៉ុន្តែគឺជាសមត្ថកិច្ចរបស់តុលាការ។*

*លោកបណ្ឌិត រស់ ចាន់ត្រាបុត្រ អនុប្រធានរាជបណ្ឌិតសភាកម្ពុជា សំដែងនូវការសោកស្តាយចំពោះទង្វើអាក្រក់របស់ឧកញ៉ាខ្លះដែលជិះជាន់បំពានច្បាប់ និងធ្វើអោយប៉ះពាល់កិត្តិយសដល់ឧកញ៉ាដទៃទៀត។ ប៉ុន្តែ លោកបានវាយតម្លៃថា មានតែឧកញ៉ាតិចតួចប៉ុណ្ណោះដែលប្រព្រឹត្តិទង្វើមិនត្រឹមត្រូវនេះ។*

*ចំណែកឯលោក សុន ឆ័យ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានរិះគន់អំពើពុករលួយដែលបានកើតមាន ទាក់ទងនឹងនីតិវិធីផ្តល់គោរមងារជាឧកញ៉ានេះ។ «ឧកញ៉ាមួយចំនួនគ្រាន់តែចង់បានងារនេះ ដើម្បីប្រព្រឹត្តិទង្វើខុសច្បាប់តាមទំនើងចិត្តរបស់ខ្លួនតែប៉ុណ្ណោះ។»*

### គោរម្យងារដែលមិនមានផ្លាស់ប្តូរអ្វីសោះ?

បន្ទាប់ពីមានការស្នើសុំពីរាជរដ្ឋាភិបាលផ្តល់គោរមងារជាឧកញ៉ាអស់រយៈពេល ជាង១០ឆ្នាំមក ហើយនោះ ឧកញ៉ា ស៊ីវ គង់ទ្រីយល់ឃើញថាមិនមានអ្វីដែលខុសប្លែក ចំពោះការមានគោរមងារ នេះទេ។ លោកបានពន្យល់បន្ថែមទៀតថា «សព្វថ្ងៃនេះ មានឧកញ៉ាសជាច្រើន...»។

លោកឧកញ៉ា ម៉ុង រិទ្ធី វាយតម្លៃថា «ការក្លាយខ្លួនជាឧកញ៉ា មិនបានធ្វើអោយមុខរបររកស៊ីរបស់ អ្នកមានការផ្លាស់ប្តូរអ្វីឡើយ! ទាំងអស់នេះអាស្រ័យទៅតាមកាលៈទេសៈ។ ឧទាហរណ៍ខ្លួនខ្ញុំផ្ទាល់ ខ្ញុំបានក្លាយជាឧកញ៉ានៅឆ្នាំ១៩៩៦ ខណៈពេលដែលប្រទេសជាតិមិនទាន់មានសន្តិភាពពេញ លេញនៅឡើយ»។ លោកបានបន្ថែមទៀតថា លោកបានចំណាយធនធានជិត៤លានដុល្លារ សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ។ ទោះបីជាយើងមិនអាចប្រើគោរងារជាឧកញ៉ានេះ ទៅតាម ទំនើងចិត្តរបស់យើងក៏ដោយ ក៏លោកទទួលស្គាល់ថា វាប្រៀបបានដូចជាជិះយន្តហោះលំដាប់ថ្នាក់ លេខមួយ»។

### ឋានានុក្រមឧកញ៉ា

តើ «អ្នកឧកញ៉ា» មានទ្រព្យសម្បត្តិជាង «លោកឧកញ៉ា» រឺ? តាមមតិមួយចំនួន បុព្វបទ «អ្នក» បញ្ជាក់ថាមនុស្សនោះបានទទួលគោរមងារជាឧកញ៉ា តាំងពីយូរមកហើយ និងចូលរួមវិភាគទាន ជាអំណោយច្រើនជាង «លោកឧកញ៉ា» និង «ឧកញ៉ា» ផ្សេងៗទៀតដែរ។ ប៉ុន្តែ លោក ធៀន ម៉ៅ ប្រធាននាយកដ្ឋានគ្រឿងឥស្សរិយយសបានលើកឡើងថាអនុក្រឹត្យមិនបានបែងចែកភាពខុស គ្នាទេ។ «មនុស្សមួយចំនួនបានបំពោងគោរមងាររបស់ខ្លួន ដោយបន្ថែម ពាក្យ«អ្នក»នៅពីមុខ។ ប៉ុន្តែ នៅក្នុងអនុក្រឹត្យ មានតែពាក្យ «ឧកញ៉ា» ប៉ុណ្ណោះ...។ លោកបានអោយយោបល់ថា យើងត្រូវ ធ្វើការដើម្បីបង្កើតឋានានុក្រមឧកញ៉ា ដែលនឹងត្រូវកំណត់ទៅតាមចំនួនទឹកប្រាក់វិភាគទានរបស់ ពួកគេចំពោះរដ្ឋ ជាមួយនឹងព្រះបរមរាជវាំង»។

### ឈ្មោះឧកញ៉ាដ៏មានឥទ្ធិពលមួយចំនួន៖

-គិត ម៉េង ប្រធានសភាពាណិជ្ជកម្មភ្នំពេញ (CCPP)និងជាប្រធានក្រុមហ៊ុន Royal Group (រួមមាន ក្រុមហ៊ុនទូរស័ព្ទ Mobitel និងធនាគារ ANZ Royal

-ម៉ុង រិទ្ធី សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា អនុប្រធាន CCPP និងជាប្រធាន ក្រុមហ៊ុន ម៉ុង រិទ្ធី គ្រុប

-ឡាវ ម៉េង ឃីម សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមហ៊ុន KT

Pacific Group

-សុខ គង់ ប្រធានកិត្តិយស CCPP និងជាអគ្គនាយកក្រុមហ៊ុនសូគីមិច និងជាទីប្រឹក្សារាជរដ្ឋាភិបាល

-ម៉ែន សារុន សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធាន CCPP និងជាប្រធាន ម៉ែន សារុន នីហរណ៍ អាហរណ៍

## តារាងមេដាយ

អនុក្រឹត្យបានកំណត់ថា អ្នកណាមានសិទ្ធិទទួលបានមេដាយអ្វី សម្រាប់ការស្តាបនាជាតិ៖

-អំណោយជាថវិកានរឺសម្ភារ: ដែលមានតម្លៃលើសពីមួយសែនដុល្លារ នឹងទទួលបានមេដាយមាស និងគោរមងារជាឧកញ៉ា

-អំណោយ ចាប់ពី មួយម៉ឺនដល់មួយសែនដុល្លារ នឹងទទួលបានត្រឹមតែមេដាយមាសប៉ុណ្ណោះ

-អំណោយ ចាប់ពី ៥០០០ ដល់ ១០ ០០០ដុល្លារ នឹងទទួលបានមេដាយប្រាក់

-អំណោយ ចាប់ពី ១០០០ ដល់ ៥០០០ដុល្លារ នឹងទទួលបានមេដាយសំរិទ្ធិ

-អំណោចាប់ពី ៥០០ ដល់១០០០ នឹងទទួលបានវិញ្ញាបនបត្រចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី

ដកស្រង់ចេញពី www.ka-set.info